ROYAL
CHILDREN'S
HOSPITAL

Cambodian

# ខ្យល់អាកាសល្អសំរាប់លោកអ្នក និងកូនរបស់លោកអ្នក

(Clean air for you and the kids)

មន្ទីរពេទ្យ Royal Children's Hospital គាំទ្របរិដ្ឋានដែលឥតមានផ្សែងបារីសំរាប់កុមារ។ បរិដ្ឋានដែលឥតមានផ្សែងបារីគឺល្អប្រសើរសំរាប់សុខភាពរបស់កុមារ។

យើងសង្ឃឹមថាការអញ្ជើញមកមន្ទីរពេទ្យ Royal Children's Hospital របស់កូនលោកអ្នក អាចជាឱកាសមួយសំរាប់លោកអ្នក និងគ្រួសាររបស់លោកអ្នកដើម្បីធ្វើការឈោងចាប់យកទីលំនៅ និងឡានរបស់លោកអ្នកឲ្យបានជាកន្លែងឥតមានផ្សែងបារី។

អាគារ និងបរិវេណនៃមន្ទីរពេទ្យ Royal Children's Hospital ឥឡូវនេះគឺជាកន្លែងដែលឥតមានផ្សែងបារី។ សន្លឹកពត៌មាននេះផ្តល់ជូនពត៌មានអំពីគោលការណ៍របស់មន្ទីរពេទ្យស្តីអំពីការជក់បារី ទីកន្លែងដែលត្រូវទៅប្រសិនបើលោកអ្នកប្រាថ្នាចង់ជក់បារី និងកិច្ចបំរើទាំងឡាយដែលមានផ្តល់ជូន ប្រសិនបើលោកអ្នកចាប់អារម្មណ៍ចង់ដឹងច្រើនថែមទៀតអំពីការឈប់ជក់បារី។

យើងដឹងថាការមានកូននៅក្នុងមន្ទីរពេទ្យគឺជាពេលមានភាពតានដឹង ហើយយើងយល់ឃើញថាមនុស្សជាច្រើនត្រឡប់ទៅជាចេះជក់បារីក្នុងពេលមានភាពតានតឹង។ មនុស្សជំទង់ភាគច្រើនដែលជក់បារី ញៀននឹងជាតិនីកូទីន ហើយយើងក៏ដឹងផងដែរថាលោកអ្នកមិនចង់ជ្រើសរើសនៅទីនេះទេ។

ដោយព្រោះតែមូលហេតុទាំងនេះ ជាជាងបង្ខំឲ្យមានការហាមកុំឲ្យជក់បារីទាំងស្រុងនៅក្នុងបរិវេណមន្ទីរពេទ្យ (មិនអនុញ្ញាតឲ្យជក់បារីនៅក្នុងអាគារឡើយ) មន្ទីរពេទ្យបានសម្គាល់ឃើញកន្លែងទាំងបីនេះដែលត្រូវបានអនុញ្ញាតឲ្យជក់បារី។

ប្រសិនបើលោកអ្នកជ្រើសរើសជក់បារី ក្នុងកាលកូនរបស់លោកអ្នកកំពុងស្នាក់នៅក្នុងមន្ទីរពេទ្យ Royal Children's Hospital យើងស្នើសុំឲ្យលោកអ្នកជក់បារីតែក្នុងកន្លែងជ្រើសតាំងខាងក្រៅប៉ុណ្ណោះ។ កន្លែងទាំងនេះគឺនៅឆ្ងាយពីច្រកផ្លូវខ្យល់អាកាសរបស់មន្ទីរពេទ្យ។ សភាពគ្រោះថ្នាក់នៃការជក់បារីនៅតាមកន្លែងឯទៀត គឺថាខ្យល់អាកាសដែលមានពេញទៅដោយផ្សែងបារីនឹងបក់ចូលទៅក្នុងមន្ទីរពេទ្យ ដែលអាចប៉ះពាល់ដល់សុខភាពរបស់កូនក្មេងឈឺរបស់យើង នៅក្នុងមន្ទីរថែទាំដែលមានកំរិតខ្លាំង និងបន្ទប់អ្នកជម្ងឺឯទៀត។

ផែនទីបង្ហាញប្រាប់កន្លែងជ្រើសតាំងដែលឥតមានផ្សែងបារី គឺមានបង្ហាញនៅពីលើសន្លឹកពត៌មាននេះ។ ជនណាដែលត្រូវបានគេឃើញជក់បារីនៅក្រៅកន្លែងទាំងនេះ នឹងត្រូវបានប្រាប់ឲ្យពន្លត់បារីរបស់ខ្លួន ឬឲ្យដើរចេញពីកន្លែងនោះ។

នេះត្រូវបានគេទទួលដឹងថាបរិដ្ឋានផ្សែងបារី គឺផ្សែងបារីពីអ្នកជក់ឯទៀត វាទាក់ទិនជាមួយនឹងជម្ងឺមាននៅក្នុងចំណោមកុមារ។

ផលិតផលចេញពីផ្សែងបារីរបស់មាតាបិតា ត្រូវបានគេរកឃើញភាពមិនផ្លាស់ប្តូរមាននៅក្នុងការធ្វើតេស្តឈាម ទឹកនោម និងទឹកមាត់ក្នុងចំណោមពួកក្មេងតូចៗទៀតផង។

ជំពោះកូនក្មេងវិញ ការដាក់ឲ្យនៅក្បែរផ្សែងបារីរបស់មនុស្សឯទៀតគឺទាក់ទិនជាមួយនឹងបញ្ហាដើមទ្រូងទាំងឡាយ មានដូចជា:

- ជម្ងឺហឺត
- ជម្ងឺរលាកទងសួត
- ជម្ងឺរលាកសួត
- ជម្ងឺរលាកបំពង់ក
- ដំបៅត្រចៀក
- ជម្ងឺរលាកបំពង់ក
- ជម្ងឺទារកស្លាប់ភ្លាមៗនៅពេលកំពុងគេង
- ដំបៅបាក់តេរីធ្ងន់ធ្ងរ

កុមារដែលរស់នៅក្នុងផ្ទះដែលមាតាបិតាខ្លួនជក់បារី នោះទំនងជាត្រូវទៅមន្ទីរពេទ្យដោយមានរោគទាំងនេះ។

មាតាបិតាភាគច្រើនដែលជក់បារីនិយាយថាគេប្រាថ្នាថាមិនបានចាប់ផ្តើមជក់បារីទាល់តែសោះ។ កុមារដែលរស់នៅ ហើយធំលូតលាស់ជាមួយមាតាម្នាក់ ឬមាតាបិតាឯទៀតដែលជក់បារី នោះមានទំនងច្រើននឹងក្លាយទៅជាអ្នកជក់ខ្លួនគេ។ ហេតុដូច្នោះហើយមាតាបិតាដែលឈប់ជក់បារីគឺគេបានបំពេញកិច្ចការដ៏ត្រឹមត្រូវសំរាប់សុខភាពរបស់ខ្លួន ហើយជាសំខាន់បំផុតគឺជួយផ្សព្វផ្សាយសុខភាពអនាគតរបស់កូនខ្លួន។ មាតាបិតាមានមុខនាទីជាមនុស្សគំរូយ៉ាងខ្លាំងក្លាសំរាប់កុមារ ថ្វីបើលោកអ្នកអាចនិយាយប្រាប់ឲ្យកូនរបស់លោកអ្នកឈប់ជក់បារីជាយ៉ាងណាក្តី នោះគេទំនងជាចម្លងតាមនូវអ្វីដែលលោកអ្នកធ្វើ ជាជាងស្តាប់ទៅលើអ្វីដែលលោកអ្នកនិយាយប្រាប់គេ។

**តើមានកិច្ចបំរើណាខ្លះសំរាប់អស់អ្នកដែលមានបំណងចង់ឈប់ជក់បារី?**

មានមនុស្សជំទង់បីនាក់ ក្នុងចំណោមមនុស្សជំទង់បួននាក់ដែលជក់បារី មានបំណងចង់ឈប់ជក់បារីប្រសិនបើគេអាចធ្វើទៅបាន ហើយមានមនុស្សច្រើនជាងពាក់កណ្តាលនៅក្នុងចំណោមមនុស្សទាំងនោះគិតអំពីរឿងនេះ។ ប្រហែលជាលោកអ្នកអាចប្រើការអញ្ជើញមកមន្ទីរពេទ្យ Royal Children's Hospital របស់លោកអ្នកដើម្បីបំផ្លាស់បំប្រែគំនិតនេះ ឲ្យបានក្លាយទៅជាការប្រព្រឹត្តវិញ! យើងសូមលើកទឹកចិត្តលោកអ្នកឲ្យនិយាយជាមួយវេជ្ជបណ្ឌិតរបស់កូនលោកអ្នក ឬគិលានុបដ្ឋាយិកាអំពីអ្វីខ្លះដែលលោកអ្នកអាចធ្វើដើម្បីឈប់ជក់បារី។

យើងក៏សូមណែនាំផងដែរ
លេខទូរស័ព្ទឈប់ជក់បារី Quitline: 131 848

នេះគឺជាលេខទូរស័ព្ទកិច្ចបំរើផ្តល់ពត៌មាន និងឱវាទផ្តល់ជូនដោយ QUIT វិចតូរីយ៉ា។ លោកអ្នកនឹងនិយាយទៅកាន់បុគ្គលិកដែលមានការហ្វឹកហ្វឺនដែលគេអាចផ្តល់ពត៌មានជូនលោកអ្នក និងកិច្ចបំរើផ្សេកៗឥតគិតថ្លៃមួយចំនួន។ ថ្លៃទូរស័ព្ទគឺអស់តម្លៃដូចនៅក្នុងតំបន់។

វេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់លោកអ្នក GP មានជំនាញការក្នុងការជួយប្រជាជនដែលមានបំណងចង់បញ្ឈប់ការជក់បារី។ សូមនិយាយទៅកាន់គេអំពីជម្រើសផ្សេងៗទាំងឡាយដែលមានផ្តល់ជូន រាប់បញ្ចូលទាំងថ្នាំពេទ្យនានាដូចជា Zyban និងថ្នាំប្រើជំនួសជាតិនីកូទីន (ពោលគឺ បន្ទះបិទ និងជាតិស្ករកៅស៊ូ) ព្រមទាំងការផ្គត់ផ្គង់ឯទៀត។

ផលិតដោយ: Fresh Air for The Kids

ដោយមានការរួមសហប្រតិបត្តិពី: Centre for Adolescent Health; Royal Children's Hospital


AMBULANCE BAY
EMERGENCY ENTRANCE
GATEHOUSE STREET
SMOKING
SOUTH EAST BUILDING


RECEPTION
RAMP UP
UP
DOWN
TELEPHONE
LIFTS
MCDONALDS
ATM
MAIN ENTRANCE
SMOKING


PLAYGROUND
HELIPAD
(ROYAL PARK)
SQUASH COURT
SMOKING
CAFÉ GARDEN
TO
GATEHOUSE
STREET
CAR PARK
CAFÉ – REAR FIRST FLOOR MAIN BUILDING